គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

Vision: A democratic society where democratization in particular democratic elections are promoted and qualified to bring benefit to people.

*រាជធានីភ្នំពេញ ថ្ងៃព្រហស្បតិ៍ ៦រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤*
*ត្រូវនឹង ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០*

# សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃការសង្កេតដោយសង្ខេប ស្តីពី ការឃ្លាំមើលយេនឌ័រផ្នែកនយោបាយៈ សភា និងតំណាងរាស្ត្រស្ត្រី និងការផ្តល់អំណាចឱ្យស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន

បញ្ហាវិសមភាពនៃតំណាងជាប់ឆ្នោតជាអ្នកដឹកនាំជាស្ត្រី និងបុរសនៅតែបន្តនៅក្នុងប្រទេសកម្ពុជា ។ ជាក់ស្តែង ស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំ គឺមានចំនួនតិចតួចទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ខណៈដែលបុរសមានចំនួនច្រើនលើសលុបក្នុងរចនាសម្ព័ន្ធនៃការដឹកនាំ ។ បញ្ហាវិសមភាពយេនឌ័រនេះ គឺដោយសារៈ (១) ខ្វះនូវគោលនយោបាយជាក់លាក់មួយចំនួន និងខ្វះការអនុវត្តច្បាប់ និងយន្តការដែលមានស្រាប់មួយចំនួនឲ្យបានតឹងរ៉ឹង និងប្រសិទ្ធភាពដើម្បីគាំទ្រ និងផ្តល់ឱកាសឲ្យស្ត្រីចូលរួមដោយស្មើភាព ពេញលេញក្នុងកិច្ចការសាធារណៈ និងវិស័យនយោបាយ ។ (២) បន្តការរើសអើងមកលើស្ត្រីក្នុងតួនាទីដឹកនាំ និងកិច្ចការនយោបាយ ។ (៣) រាជរដ្ឋាភិបាលកម្ពុជា ខកខានការអនុវត្តកាតព្វកិច្ចជារដ្ឋភាគីនៃអនុសញ្ញាអន្តរជាតិ ស្តីពី « ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ » (ស៊ី-ដរ/CEDAW)ដែលកម្ពុជាជារដ្ឋហត្ថលេខីតាំងពីឆ្នាំ១៩៩២ ។ (៤) អ្នកដឹកនាំជាបុរសនៅតែចង់រក្សាអំណាចនយោបាយ និងមិនចង់ចុះចេញពីតំណែង។ ក្នុងនាមជារដ្ឋភាគីនៃអនុសញ្ញាស៊ី-ដរ រាជរដ្ឋាភិបាលកម្ពុជាបានរំលឹកថា ការរើសអើងប្រឆាំងនឹងស្ត្រី គឺរំលោភលើគោលការណ៍ស្មើភាពគ្នានៃការគោរព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស វាគឺជាឧបសគ្គចំពោះការចូលរួមរបស់ស្ត្រីស្មើភាពនឹងបុរសក្នុងជីវិតនយោបាយ សង្គម សេដ្ឋកិច្ច និងវប្បធម៌ ។ ការរើសអើងប្រឆាំងនឹងស្ត្រីបានរារាំងការរីកចម្រើនរុងរឿងនៃសង្គម និងគ្រួសារ ហើយធ្វើឲ្យមានការលំបាកកាន់តែខ្លាំងចំពោះការអភិវឌ្ឍន៍ពេញលេញនៃសក្តានុពលរបស់ស្ត្រី ។

ក្រៅពីការបន្តបញ្ហាវិសមភាពនៃតំណាង និងការអនុវត្តសិទ្ធិរវាងស្ត្រី និងបុរសនៅកម្ពុជានៅគ្រប់លំដាប់ថ្នាក់ ការសង្កេត តាមដាន និងការពិនិត្យមើលលើស្ថានភាពការងាររបស់តំណាងជាប់ឆ្នោតស្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន គឺជារបៀបវារៈសំខាន់បំផុតដែលត្រូវស្វែងយល់ និងឃ្លាំមើលដោយយកចិត្តទុកដាក់ពីគ្រប់ភាគីពាក់ព័ន្ធ ប្រយោជន៍លើកស្ទួយ ការពារការចូលរួមធ្វើសេចក្តីសម្រេចខាងនយោបាយ និងការដឹកនាំ រួមទាំងការបំពេញ និងទទួលបាននូវតួនាទី ភារកិច្ច និងសិទ្ធិអំណាចពេញលេញរបស់ស្ត្រីផងដែរ ។

របាយការណ៍ឃ្លាំមើលយេនឌ័រផ្នែកនយោបាយរបស់ខុមហ្វ្រែលប្រចាំឆ្នាំ២០១៩នេះ ត្រូវបានធ្វើឡើងតាមវិធីសាស្ត្រសង្កេតការណ៍ដោយផ្ទាល់ តាមដាន ឃ្លាំមើល ការសម្ភាសន៍តាមបែបសំណេះសំណាល (Semi-

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

Interview) ការសម្ភាសន៍ផ្ទាល់ (Interview) និងការពិនិត្យមើលលើស្ថានភាព និងការងាររបស់តំណាងស្ត្រីជាប់ឆ្នោតទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ព្រមទាំងអ្នកនយោបាយស្ត្រីផងដែរ។

## ***អ្នកតំណាងរាស្ត្រស្ត្រីឡើងបញ្ចេញមតិក្នុងកិច្ចប្រជុំពេញអង្គរដ្ឋសភា***

សម្រាប់ឆ្នាំទី១ នីតិកាលទី៦នៃរដ្ឋសភា ឆ្នាំ២០១៩ ក្នុងរយៈពេលចាប់ពីខែកញ្ញា ឆ្នាំ២០១៨ រហូតដល់ខែសីហា ឆ្នាំ២០១៩ គណបក្សប្រជាជនកម្ពុជាតែមួយគត់ដែលបានឈ្នះឆ្នោតមានអាសនៈសភាទាំងអស់ និងមានតំណាងរាស្ត្រស្ត្រីនៅក្នុងរដ្ឋសភាជាតិ ។

តំណាងរាស្ត្រស្ត្រីដែលបានឡើងបញ្ចេញមតិក្នុងកិច្ចប្រជុំសភាពេញអង្គសម្រាប់ឆ្នាំទី១ នីតិកាលទី៦នេះមានចំនួន ១នាក់ ស្មើនឹង ៣,៨៤% នៃតំណាងរាស្ត្រស្ត្រីសរុប២៦នាក់ ខណៈដែលតំណាងរាស្ត្រប្រុសមានចំនួន ១១នាក់ ស្មើនឹង ១១,១១% នៃតំណាងរាស្ត្រប្រុសសរុប ៩៩នាក់ ។ ចំនួននៃការឡើងបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រទាំងស្ត្រី និងបុរស គឺមានកម្រិតទាបបំផុត ៩,៦០% បើធៀបនឹងចំនួនអ្នកតំណាងរាស្ត្រសរុប ១២៥នាក់ ចំណែកឯការបញ្ចេញមតិ គឺ មានតែការគាំទ្រច្បាប់ និងកោតសរសើរសមិទ្ធផល និងការដឹកនាំរបស់រាជរដ្ឋាភិបាល ប៉ុន្តែ មិនសូវឃើញតំណាងរាស្ត្រណាម្នាក់ជំទាស់ រិះគន់ និងសួរដេញដោលដោយស៊ីជម្រៅឡើយ។

*លោកជំទាវ* ***ឡោក ខេង*** អ្នកតំណាងរាស្ត្រស្ត្រីនៅមណ្ឌលរាជធានីភ្នំពេញ បានឡើងបញ្ចេញមតិចំនួន ១ដងក្នុងន័យ**វិជ្ជមាន** ដោយផ្តោតទៅលើការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ និងបានបង្ហាញពីការគាំទ្រច្បាប់នេះដែលបាននាំផលប្រយោជន៍ជូនប្រជាពលរដ្ឋ និងធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនទៅមុខយ៉ាងលឿន ព្រមទាំងគាំទ្រសមិទ្ធផល កិច្ចខិតខំប្រឹងប្រែងពាក់ព័ន្ធនឹងការកសាង និងការជួយឧបត្ថម្ភផ្សេងៗដល់ប្រជាពលរដ្ឋ។

ក្នុងឆ្នាំទី១ នីតិកាលទី៦នៃសភាឯកបក្សនេះ **បញ្ហាស្ត្រី និងកុមារ** មិនត្រូវបានលើកយកមកដាក់ក្នុងរបៀបវារៈនៃកិច្ចប្រជុំសភាពេញអង្គទេ ហើយរាល់កិច្ចពិភាក្សាពុំបានឆ្លុះបញ្ចាំងពីផលប្រយោជន៍ និងផលប៉ះពាល់ដល់ស្ត្រី និងកុមារឡើយ ។

## ***អ្នកតំណាងរាស្ត្រស្ត្រីចុះមូលដ្ឋាន***

សកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ក្នុងរយៈពេលចាប់ពីខែកញ្ញា ឆ្នាំ២០១៨ រហូតដល់ ខែសីហា ឆ្នាំ២០១៩ មានតំណាងរាស្ត្រចំនួន**៦៤នាក់** ក្នុងនោះមាន**ស្ត្រី១៤នាក់**ក្នុងចំណោមតំណាងរាស្ត្រសរុប ១២៥នាក់បានចុះមូលដ្ឋានសរុបចំនួន**១១៥៦លើក** ។ ចំនួននេះបាន**ថយចុះ**ចំនួន **៥០៩លើក** ពី **១៦៦៥លើក** នីតិកាលទី៥ ឆ្នាំ២០១៦[1] មកត្រឹម **១១៦៥លើក** នីតិកាលទី៦ ក្នុងឆ្នាំទី១ ។

ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រស្ត្រីបានចុះបេសកកម្ម **ប្រហាក់ប្រហែលនឹង**ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រប្រុសដែលបានចុះបេសកកម្ម **គឺ ៥៣,៨៤%** ស្មើនឹងចំនួនតំណាងរាស្ត្រស្ត្រី១៤នាក់ក្នុងចំណោមសមាជិកសភាស្ត្រី២៦នាក់ ច្រើនជាងបន្តិចភាគរយរបស់អ្នកតំណាងរាស្ត្រប្រុសចំនួន **៥០,៥០%** ស្មើនឹង៥០នាក់ក្នុងចំណោមសមាជិកសភាប្រុស៩៩នាក់ ។ បើប្រៀបធៀបនឹងនីតិកាលទី៥ដែលគណបក្សចំនួនពីរមានអាសនៈនៅក្នុងរដ្ឋសភា ភាគរយអ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្មមាន**ការថយចុះខ្លាំង**ពី ៨៣,៣៣% នីតិកាលទី៥ ឆ្នាំ២០១៦ មកត្រឹម៥៣,៨៤% នីតិកាលទី៦ ឆ្នាំ២០១៩ ខណៈដែលភាគរយអ្នកតំណាងរាស្ត្រ

[1] របាយការណ៍ខុមហ្វ្រែល ឃ្លាំមើលយេនឌ័រផ្នែកនយោបាយ៖ សភា និងតំណាងរាស្ត្រស្ត្រី និងស្ត្រីក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦ ចេញផ្សាយនៅខែមីនា ឆ្នាំ២០១៧ (COMFREL's Website: www.comfrel.org)

បុរសចុះបេសកកម្មក៏មាន**ការថយចុះខ្លាំងដែរ** គឺពី ៧៨,៧៩% នីតិកាលទី៥ ឆ្នាំ២០១៦ មកត្រឹម ៥០,៥០% នីតិកាលទី៦ ឆ្នាំ២០១៩។

តំណាងរាស្ត្រស្ត្រីចំនួន១៨នាក់បានធ្វើសកម្មភាពនៅមូលដ្ឋានសរុបចំនួន **២២៩លើក** ។ ចំនួនសកម្មភាពនេះ ***បានថយចុះ ១១០លើក*** ពី **៣៣៩លើក** នីតិកាលទី៥ ឆ្នាំ២០១៦ មកត្រឹម **២២៩លើក** នីតិកាលទី៦ ក្នុងឆ្នាំ២០១៩ ។ បើប្រៀបធៀប ពីគោលបំណងមួយទៅគោលបំណងមួយនៃការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី បង្ហាញឲ្យឃើញថា មានការ***ខុសគ្នាឆ្ងាយ***រវាងតួលេខនៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាដែលមានចំនួន**១៧៣លើក (៧៥,៥៤%)** ជាមួយនឹងការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋមានចំនួន**0លើក (0%)**។ ការចុះពង្រឹងផ្ទៃក្នុង និង បណ្តាញគណបក្សចំនួន ៣៥លើក។ ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំមានចំនួន២១លើក ។* តួលេខនេះ នៅតែបង្ហាញយ៉ាងច្បាស់ថា សកម្មភាពនៃ*ការចុះសំណេះ សំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានានៅតែជាសកម្មភាពអាទិភាព និងសកម្មជដែល ខណៈដែលការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សក៏ជាសកម្មភាពអាទិភាពផងដែរ ។*

តំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្ម***ច្រើនជាងគេបំផុត*** នៅក្នុងឆ្នាំទី១ នីតិកាលទី៦នេះ គឺ **លោកជំទាវ ម៉ែន សំអន** តំណាងរាស្ត្រមណ្ឌលខេត្តស្វាយរៀងមានចំនួន **៥៨លើក គឺមានការកើនឡើងជិត៤ដង** បើធៀបនឹងនីតិកាលទី៥ ឆ្នាំ២០១៦ មានចំនួនតែ ១៥លើក ។ អ្នកដែល***ច្រើនបន្ទាប់*** គឺ **លោកជំទាវ បាន ស្រីមុំ** តំណាងរាស្ត្រមណ្ឌលខេត្តប៉ៃលិន មានចំនួន **៥២លើក គឺបានកើន*ឡើងខ្លាំង* ១៣ដង** បើធៀបនឹងនីតិកាលទី៥ ឆ្នាំ២០១៤ មានចំនួនតែ ៤លើក ។ អ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះមូលដ្ឋាន***ច្រើនបង្គួរ*** គឺ **លោកជំទាវ ឡោក ខេង** តំណាងរាស្ត្រមណ្ឌលរាជធានីភ្នំពេញ មានចំនួន **៣៨លើក** គឺ***ប្រហាក់ប្រហែល***នឹងនីតិកាលទី៥ ឆ្នាំ ២០១៦ មានចំនួន ៣៤លើក ។

## *ស្ថានភាពអ្នកនយោបាយស្ត្រីកម្ពុជា*

ចន្លោះពីដើមឆ្នាំ ដល់ពាក់កណ្តាលឆ្នាំ២០១៩ អ្នកនយោបាយស្ត្រីដែលប្រើប្រាស់សិទ្ធិនយោបាយរបស់ខ្លួន និងសិទ្ធិស្ត្រីដើម្បីចូលរួមក្នុងដំណើរការប្រជាធិបតេយ្យនៅប្រទេសកម្ពុជាត្រូវបានប្រឈមការចោទប្រកាន់តាមផ្លូវតុលាការ ការរើសអើង ការឃាយី ការគំរាមកំហែង និងការរិតត្បិតពីសំណាក់អាជ្ញាធរ សូម្បីតែការជួបប្រជុំគ្នា ការពិភាក្សាគ្នាអំពីរឿងនយោបាយរបស់ស្ត្រីក៏ត្រូវបានរំខាន ដូចជា សារព្រមានរបស់លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន**ចំពោះក្រុមស្ត្រីជួបប្រជុំគ្នាពិភាក្សារឿងនយោបាយ ។ អតីតចៅសង្កាត់អូចារ ខេត្តបាត់ដំបងត្រូវបានតុលាការកោះហៅជាបន្តបន្ទាប់ ។ ការជួបជុំទទួលទានអាហាររួមគ្នារបស់អតីតសមាជិក និងមន្ត្រីបក្សសង្គ្រោះជាតិត្រូវបានអាជ្ញាធររំខាន មិនអនុញ្ញាត ។ ក្រុមស្ត្រីជាប់ឆ្នោតជាមេឃុំ សមាជិកក្រុមប្រឹក្សាខេត្ត និងស្រុកនៃអតីតគណបក្សសង្គ្រោះជាតិក្នុងខេត្តកំពង់ស្ពឺ ចំនួន **៦រូប**ត្រូវបង្ខំចិត្តរត់គៀសខ្លួន ដើម្បីសុវត្ថិភាពចៀសពីការធ្វើទុក្ខបុកម្នេញពីអាជ្ញាធររបបក្រុងភ្នំពេញ ។

សកម្មភាពរបស់រដ្ឋាភិបាល និងទង្វើរបស់អាជ្ញាធរ ជាការប្រព្រឹត្តិផ្ទុយនឹងអនុសញ្ញាស៊ី-ដរ មាត្រា៣ចែងថា « *ក្នុងគ្រប់វិស័យ ជាពិសេសវិស័យ នយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីធានាការអភិវឌ្ឍន៍ និងការរីកចំរើនពេញលេញរបស់ស្ត្រី ដើម្បីធានាឲ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផលសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដោយសមភាពជាមួយបុរស* »។ និងមាត្រា៧ បានចែងថា « *រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្រប ដើម្បីលុបបំបាត់ចោលការរើសអើងប្រឆាំងនឹងស្ត្រីក្នុងជីវភាពនយោបាយ និងសាធារណៈរបស់ប្រទេស ។...* » ។ ទង្វើទាំងនេះ ក៏ជាការរំលោភបំពានមកលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានការពារសិទ្ធិសេរីភាពបញ្ចេញមតិ និងការជួបប្រជុំដែលមានចែងក្នុងមាត្រា៤១ « *ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារ*

*ព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។...»* និងបានរំលោភបំពានយ៉ាងខ្លាំងចំពោះ កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៩ កថាខណ្ឌ២ ចែងថា *« ជនគ្រប់រូបមាន សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ។...»* ។

## ការរើសអើង និងការចូលរួមធ្វើសេចក្តីសម្រេចនៅថ្នាក់ឃុំ សង្កាត់

អាកប្បកិរិយារើសអើងចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់មានការ**ថយចុះខ្លាំង** ខណៈដែលមានការគាំទ្រ និងលើកកម្ពស់ស្ត្រីខ្លាំងពីបុរសក្រុមប្រឹក្សាឃុំ សង្កាត់ និងមេភូមិ ដោយបុរសទាំងនោះមានការផ្លាស់ប្តូរអាកប្បកិរិយាឲ្យតម្លៃស្ត្រី បានយល់ដឹងពីយេនឌ័រ គោរពសិទ្ធិស្ត្រី និងបានសហការល្អជាមួយស្ត្រីក្នុងការធ្វើការងារ ការដោះស្រាយបញ្ហា និងការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន។ ទោះបីយ៉ាងណាក៏ដោយ ការរើសអើងចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួននៅតែបន្តមាននៅឡើយ ដោយបុរសក្រុមប្រឹក្សាឃុំ សង្កាត់ខ្លះមិនចង់សហការ និងមានការរិះគន់ចំពោះស្ត្រី ។ បើប្រៀបធៀបនឹងអាណត្តិទី៣ ឆ្នាំ២០១៥ ការគាំទ្រស្ត្រី ការលើកទឹកចិត្តស្ត្រី ការឲ្យតម្លៃស្ត្រី និងការសហការជាមួយស្ត្រីមានការ**កើនឡើង** ពី ៨២,៩២% នៅឆ្នាំ២០១៥ (អាណត្តិទី៣) ឡើងដល់ ៩៧,២២% នៅឆ្នាំ២០១៩ (អាណត្តិទី៤) ខណៈដែលការរើសអើងមានការថយចុះ គឺពី ១២,១៩% ឆ្នាំ២០១៥ មកត្រឹម ២,៧៧% នៅឆ្នាំ២០១៩។

ចំណែកឯការរើសអើងទាក់ទងនឹងការប្រគល់តួនាទី ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ទៅសមាជិកស្ត្រីស្របតាមតួនាទីរបស់ខ្លួននោះ របាយការណ៍ខុមហ្វ្រែលរកឃើញថា ប្រធានក្រុមប្រឹក្សាបានប្រគល់តួនាទី ភារកិច្ចជូនស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់***ភាគច្រើន***ដូចមានចែងក្នុងច្បាប់ ខណៈដែលស្ត្រីក្រុមប្រឹក្សាឃុំ**ភាគតិចមិនត្រូវបាន**ប្រធានក្រុមប្រឹក្សាឃុំប្រគល់តួនាទី ភារកិច្ចឲ្យខ្លួនទាល់តែសោះ ។ បើប្រៀបធៀបនឹងឆ្នាំ ២០១៥ ការរើសអើងមិនប្រគល់ភារកិច្ចជូនដល់សមាជិកស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ មានការ***ថយចុះ*** ពី ៩,៧៥% ឆ្នាំ២០១៥ (អាណត្តិទី៣) មកត្រឹម ២,៧៧% ឆ្នាំ២០១៩ (អាណត្តិទី៤) ។ បើទោះបីតួលេខរើសអើងនេះមានការថយចុះក៏ដោយ ក៏នៅតែបង្ហាញនូវការរើសអើងកាន់តែខ្លាំងថែមទៀតមិនធ្លាប់បានឮពីមុន ដែលជាបញ្ហាបន្ទាន់ត្រូវយកចិត្តទុកដាក់ដោះស្រាយជាចាំបាច់ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាដែលមិនបានទទួល តួនាទី ភារកិច្ចរបស់ខ្លួនសោះ ឬទទួលមិនបានពេញលេញដើម្បីអនុវត្តការងារស្របតាមច្បាប់ ស្តីពី « ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ » ដែលបានធានាដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ ត្រូវតែមានភារកិច្ចទៅតាមតួនាទីរៀងៗខ្លួន ។

មានភាពប្រសើរក្នុងការចូលរួមបញ្ចេញមតិ យោបល់ និងការចូលរួមធ្វើសេចក្តីសម្រេចចិត្តរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ដូចបុរសដែរ បើទោះបីចំនួនបុរសមានច្រើនជាងស្ត្រីក៏ដោយ។ ស្ត្រីបានបង្ហាញពីសក្តានុពលរបស់ខ្លួន ភាពជឿជាក់លើខ្លួនឯង និងបានប្រើប្រាស់សិទ្ធិក្នុងការឡើងបញ្ចេញមតិយោបល់ក្នុងពេលធ្វើការងារ និងក្នុងកិច្ចប្រជុំដែលភាគច្រើនផ្តោតលើបញ្ហាស្ត្រី កុមារ និងចាស់ជរា រួមទាំងកិច្ចអភិវឌ្ឍន៍ផងដែរ ។

## ថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារនៅថ្នាក់ឃុំ សង្កាត់

ឃុំ សង្កាត់ភាគច្រើនមានភាពងាយស្រួលក្នុងការដកថវិកាមកប្រើប្រាស់លើកិច្ចការស្ត្រី និងកុមារ ប៉ុន្តែថវិកានៅមានចំនួនតិច រីឯឃុំមួយចំនួនតូចមានការពិបាកក្នុងការដកថវិកា និងតម្លាភាពថវិកានៅមានកម្រិតក្នុងឃុំ សង្កាត់មួយចំនួនផងដែរ ។

ក្នុងចំណោម ១៩ឃុំ សង្កាត់ មាន**១៦ឃុំ** មានភាព**ងាយស្រួល**ក្នុងការដកថវិកាមកប្រើប្រាស់លើកិច្ចការស្ត្រី និងកុមារ ។ រីឯ **៣ឃុំ**ទៀតមាន**ការពិបាក**ក្នុងការដកថវិកាពីរតនាគារ ស្មៀនជាអ្នកចាត់ចែងថវិកា និងពុំមានបែងចែកកញ្ចប់ថវិកាច្បាស់លាស់ទៅតាមផ្នែកនីមួយៗ ។ ឃុំដែលមានការពិបាកដកថវិកាគឺ ឃុំអញ្ចាញរូង និង

ឃុំពពេល (ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង) និង ឃុំក្រាំងស្គារ (ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង) ។ ដោយឡែកមានមតិផ្ទុយគ្នានៅក្នុង ឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ម្នាក់ថាងាយស្រួលដក ម្នាក់ទៀតថាពិបាកដក។

## ***អនុសាសន៍***

១. តំណាងរាស្ត្រស្រ្តី និងតំណាងរាស្ត្របុរសត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ម្ចាស់ឆ្នោត។

២. តំណាងរាស្ត្រស្រ្តី និងតំណាងរាស្ត្របុរសគួរតែបង្ហាញអំពីលទ្ធផលនៃការចុះបេសកកម្មតាមមូលដ្ឋានរបស់ខ្លួនដល់សាធារណជនទូទៅឲ្យបានដឹង។

៣. រាល់ការពិភាក្សា និងអនុម័តក្នុងកិច្ចប្រជុំពេញអង្គរបស់សភា ត្រូវដាក់បញ្ចូលអំពីការឆ្លើយតបនឹងយេនឌ័រនៅក្នុងច្បាប់ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

៤. រាជរដ្ឋាបាលកម្ពុជាត្រូវគោរពនូវសិទ្ធិនយោបាយរបស់ស្រ្តី និងធានាឲ្យបានក្នុងការអនុវត្តសិទ្ធិនេះ ដោយបង្កលក្ខណៈងាយស្រួលដល់ស្រ្តីធ្វើការជួបជជែកគ្នាអំពីកិច្ចការនយោបាយ និងកិច្ចការផ្សេងៗ ជាពិសេសសម្រាប់អ្នកនយោបាយស្រ្តីដែលមកពីគណបក្សប្រឆាំង និងគណបក្សផ្សេងទៀត ប្រយោជន៍គាំទ្រ និងផ្ដល់ឱកាសឱ្យស្រ្តីចូលរួមកាន់តែច្រើនក្នុងកិច្ចការនយោបាយ និងថ្នាក់សម្រេចចិត្ត ស្របតាមអនុសញ្ញាស៊ី-ដរ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា ។

៥. រាជរដ្ឋាភិបាលកម្ពុជាត្រូវពិនិត្យមើលឡើងវិញ និងយកចិត្តទុកដាក់បន្ថែមចំពោះអ្នកនយោបាយស្រ្តីនៅក្នុងគណបក្សដែលខ្លួនកំពុងដឹកនាំរដ្ឋាភិបាល ឬក៏អ្នកនយោបាយស្រ្តីផ្សេងៗដែលមានសម្លេង និងសកម្ម ឬស្រ្តីដែលបំរុងនឹងចូលរួមក្នុងវិស័យនយោបាយ ដោយលើកទឹកចិត្ត ការពារ ផ្ដល់ឱកាស និងធានាឲ្យបាននូវការចូលរួមដោយពេញលេញក្នុងកិច្ចការនយោបាយរបស់ស្រ្តី ។

៦. ក្រសួងមហាផ្ទៃ រួមទាំងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ត្រូវធានាចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ ជាពិសេសស្រ្តីទទួលបាននូវតួនាទី ភារកិច្ច និងសិទ្ធិអំណាចពេញលេញស្របតាមច្បាប់ស្តីពី «ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់»។

៧. ត្រូវផ្ដល់ការគាំទ្រគ្រប់បែបយ៉ាងឲ្យស្រ្តីជាប់ឆ្នោត និងអ្នកដឹកនាំជាស្រ្តី ដូចជា ផ្ដល់ថវិកាស្របជាមួយនឹងបញ្ហាដែលស្រ្តីកំពុងធ្វើ ផ្ដល់នូវធនធានសម្ភារៈ ធនធានមនុស្ស និងមធ្យោបាយនានា ដើម្បីបង្កលក្ខណៈងាយស្រួល និងបង្កើនប្រសិទ្ធភាពការងាររបស់ស្រ្តី ប្រយោជន៍ស្រ្តីចូលរួមដោយគុណភាពក្នុងតួនាទីជាតំណាង និងជាអ្នកដឹកនាំ ។

## ***សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖***

| | | |
|---|---|---|
| ១.លោក **គឹម ឈន** | នាយកប្រតិបត្តិខុមហ្វ្រែល | **០១២ ៩៤ ២០ ១៧** |
| ២.លោកស្រី **សឹនកេត សិរីលក្ខណ៍** | អ្នកសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រ | **០១២ ៧៧ ៥៦ ៩៦** |

**បេសកកម្ម៖ ខុមហ្វ្រែល** ជាអង្គការក្រៅរដ្ឋាភិបាល អព្យាក្រឹត្យដែលផ្តល់សិទ្ធិអំណាចដល់ប្រជាជនកម្ពុជា ដើម្បីអនុវត្តសិទ្ធិរបស់ពួកគេនៅក្នុងនយោបាយ និងការធ្វើសេចក្តីសម្រេចចិត្ត តាមរយៈការអប់រំពលរដ្ឋ និងការចូលរួមប្រកបដោយការស្ថាបនាជាមួយរដ្ឋាភិបាល និងមន្ត្រីជាប់ឆ្នោតសម្រាប់ការកែទម្រង់គោលនយោបាយ ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ និងការបង្កើនការទំនួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈ។

**MISSION: COMFREL**, as a neutral non-governmental organization, empowers Cambodian citizens to exercise their rights in politics and decision-making, through civic education, and constructive engagement with government and elected officials, for policy reforms, free and fair elections, and increased accountabilities in service delivery.